ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ: ០០៥ ....សហវ.

# សេចក្តីជូនដំណឹង

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសូមជម្រាបជូនដំណឹងដល់បេក្ខជន និង សាធារណៈជន ដែលត្រៀមប្រឡង ដើម្បីចូលបម្រើការងារនៅអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុជ្រាបថា ដើម្បីឱ្យដំណើរការប្រឡងជ្រើសរើសតាមរយៈការប្រកួតប្រជែងនេះ ប្រព្រឹត្តទៅដោយយុត្តិធម៌, មានតម្លាភាព និង មានប្រសិទ្ធភាពខ្ពស់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានខិតខំរៀបចំដំណើរការ និងនីតិវិធីនៃការប្រឡងជ្រើសរើស និងបានចាត់វិធានការតឹងរឹងបំផុត សម្រាប់ទប់ស្កាត់រាល់សកម្មភាពមិនប្រក្រតីដែលអាចកើតមានជាយថាហេតុ ។

ទោះបីដូច្នេះក៏ដោយ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុពិនិត្យឃើញថា ការប្រឡងលើកនេះ មានលក្ខណៈពិសេស និងមានវេទយិតភាពខ្ពស់ជាងការប្រឡងលើកមុនៗ ដោយសារតម្រូវការជ្រើសរើសមានចំនួនតែ ៣០០ នាក់ ប៉ុន្តែ បេក្ខជនដាក់ពាក់សុំប្រឡងមានរហូតដល់ជាង ១៥.០០០ នាក់ ដែលប្រការនេះ អាចបង្កឱ្យមានបញ្ហារសើប និង បញ្ហាសតិអារម្មណ៍ផ្សេងៗកើតមានឡើងជាយថាហេតុ ។

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុចង់បានបេក្ខជនដែលមានសមត្ថភាពខ្ពស់ ចូលបម្រើការងារ តាមរយៈ ការប្រឡងប្រជែងនេះ ។ ដូច្នេះ ក្រសួងសូមលើកទឹកចិត្តបេក្ខជនទាំងអស់ ឱ្យចូលរួមប្រឡងតាមសមត្ថភាពរៀងៗខ្លួន ។ ក្នុងស្មារតីនេះ ដើម្បីឱ្យដំណើរការប្រឡងជ្រើសរើសនេះ ប្រព្រឹត្តទៅកាន់តែមានភាពយុត្តិធម៌, មានតម្លាភាព និង ប្រសិទ្ធភាពខ្ពស់ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុបានអញ្ជើញតំណាងអង្គភាពប្រឆាំងអំពើពុករលួយ ដើម្បីមកចូលរួមសង្កេតការណ៍ និង តាមដានកិច្ចដំណើការប្រឡងជ្រើសរើសនេះ ពីដើមដល់ចប់ ។

សេចក្តីដូចបានជូនដំណឹងខាងលើ សូមបេក្ខជន និងសាធារណៈជនមេត្តាជ្រាបជាព័ត៌មាន ។

រាជធានីភ្នំពេញ, ថ្ងៃទី០៧ ខែ មិថុនា ឆ្នាំ ២០១១

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com